# ជំងឺ COVID-19
# ការពិតនៃថ្នាំបង្ការ



## ហេតុអ្វីត្រូវចាក់ថ្នាំបង្ការជំងឺ COVID-19?

- ថ្នាំបង្ការនេះកាត់បន្ថយហានិភ័យរបស់អ្នកក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 ការត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការស្លាប់ផងដែរ។ ថ្នាំបង្ការនេះក៏ជួយកាត់បន្ថយហានិភ័យរបស់អ្នកក្នុងការមានជំងឺ COVID រយៈពេលវែងផងដែរ។
- អ្នកត្រូវតែទទួលចាក់ថ្នាំបង្ការ **ឱ្យបានគ្រប់ចំនួនដូសដែលបានណែនាំទាំងអស់** (រួមទាំងដូសជំរុញ) ដើម្បីទទួលបានប្រព័ន្ធការពារល្អបំផុត។ មានការណែនាំឱ្យមនុស្សគ្រប់គ្នាដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅគួរចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ ដោយមិនគិតអំពីថាតើពួកគេបានទទួលចាក់ដូសជំរុញប៉ុន្មានដូសហើយ ឬបានទទួលចាក់ថ្នាំបង្ការប្រភេទណាមួយ ពីពេលកន្លងមក នោះទេ។




## តើអ្នកណាខ្លះដែលអាចទទួលចាក់ថ្នាំបង្ការបាន?

### មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ

- ថ្នាំបង្ការជំងឺ COVID-19 គឺ **ឥតគិតថ្លៃ** សម្រាប់មនុស្សគ្រប់គ្នា - បើទោះបីជាអ្នកមិនមានធានារ៉ាប់រងក៏ដោយ។
- អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។
- ថ្នាំបង្ការទាំងឡាយត្រូវបានណែនាំសម្រាប់មនុស្សគ្រប់រូប រួមទាំងអ្នកមានផ្ទៃពោះ ឬអ្នកកំពុងបំបៅកូនដោយទឹកដោះ និងអ្នកដែលធ្លាប់មានជំងឺ COVID-19 ផងដែរ។

## តើថ្នាំបង្ការជំងឺ COVID-19 ប្រភេទណាខ្លះ ដែលត្រូវបានណែនាំឱ្យទទួលចាក់?

### ប្រភេទ Pfizer

**អាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ៖** ចំនួន 3 ដូស
**អាយុចាប់ពី 5 ទៅ 11 ឆ្នាំ៖** ចំនួន 2 ដូស បូកនឹងដូសជំរុញដើម
**អាយុចាប់ពី 12 ឆ្នាំឡើងទៅ៖** ចំនួន 2 ដូស បូកនឹងដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ

### ប្រភេទ Moderna

**អាយុចាប់ពី 6 ខែ ទៅ 11 ឆ្នាំ៖** ចំនួន 2 ដូស
**អាយុចាប់ពី 12 ឆ្នាំ ទៅ 17 ឆ្នាំ៖** ចំនួន 2 ដូស បូកនឹងដូសជំរុញប្រភេទ Pfizer ដែលបានធ្វើឱ្យថ្មីឡើងវិញ
**អាយុចាប់ពី 18 ឆ្នាំឡើងទៅ៖** ចំនួន 2 ដូស បូកនឹងដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ

### ប្រភេទ Novavax

**អាយុចាប់ពី 12 ឆ្នាំឡើងទៅ៖** ចំនួន 2 ដូស បូកនឹងដូសជំរុញប្រភេទ Pfizer ដែលបានធ្វើឱ្យថ្មីឡើងវិញ

សូមមើលគេហទំព័រ ph.lacounty.gov/covidvaccineschedules សម្រាប់ព័ត៌មានបន្ថែម។

ប្រសិនបើអ្នក **មានប្រព័ន្ធភាពសុំាចុះខ្សោយ អ្នកអាចនឹងត្រូវការទទួលចាក់ដូសបន្ថែមទៀត** - សូមពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក។

ថ្នាំបង្ការប្រភេទ Johnson & Johnson អាចនឹងត្រូវផ្តល់ជូនសម្រាប់មនុស្សដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅក្នុង ករណីមួយចំនួន។





# ជំងឺ COVID-19
# ការពិតនៃថ្នាំបង្ការ

## របៀបទទួលចាក់ថ្នាំបង្ការ

មានទីតាំងចាក់ថ្នាំបង្ការរាប់រយកន្លែងនៅទូទាំងខោនធី LA - ទីតាំងជាច្រើនបើកបម្រើការជូននៅចុងសប្តាហ៍ និងពេលល្ងាច ហើយមិនចាំបាច់ធ្វើការណាត់ជួបទេ។



ដើម្បីស្វែងរកទីតាំងមួយដែលនៅជិតអ្នក៖

- សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/howtogetvaccinated ឬទូរស័ព្ទទៅលេខ **1-833-540-0473** ចាប់ពីម៉ោង 8:00 ព្រឹកដល់ម៉ោង 8:30 យប់។
- អ្នកក៏អាចទូរស័ព្ទទៅលេខ 2-1-1 ឬសាកសួរគ្រូពេទ្យរបស់អ្នក ឬឱសថការី (អ្នកលក់ថ្នាំពេទ្យ) ក្នុងតំបន់របស់អ្នកក៏បាន។
- មានផ្តល់ការដឹកជញ្ជូនដោយឥតគិតថ្លៃ និងការចាក់ថ្នាំបង្ការនៅតាមផ្ទះ។

អនីតិជន (ជនមិនទាន់គ្រប់អាយុ) ត្រូវការការយល់ព្រមអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ដើម្បីទទួលចាក់ថ្នាំបង្ការ។

## តើអាចមានផលប៉ះពាល់អ្វីខ្លះ?



- ផលប៉ះពាល់ទូទៅរួមមាន ការឈឺ ឡើងហើម ឬឡើងក្រហមនៅត្រង់កន្លែងដែលបានចាក់ថ្នាំបង្ការនោះ ឈឺសាច់ដុំឬឈឺតាមសន្លាក់ ហើមកូនកណ្តុរ គ្រុនក្តៅ គ្រុនរងា ឈឺក្បាល និងមានអារម្មណ៍អស់កម្លាំង។ ផលប៉ះពាល់ចំពោះកុមារតូចៗរួមមានដូចជា ឆាប់យំ ឆាប់ខឹង ងងុយគេង និងបាត់បង់ចំណង់អាហារ។
- ផលប៉ះពាល់គឺជាសញ្ញាដែលបង្ហាញថាប្រព័ន្ធភាពស៊ាំរបស់អ្នកកំពុងតែ **បង្កើតប្រព័ន្ធការពារ**។ ផលប៉ះពាល់ទាំងនេះអាចនឹងរំខានដល់អ្នកក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃមួយចំនួន ប៉ុន្តែគួរតែនឹងបាត់ទៅវិញក្នុងរយៈពេលមួយ ឬពីរថ្ងៃ បន្ទាប់ពីបានចាក់ថ្នាំបង្ការរួច។
- ផលប៉ះពាល់បែបធ្ងន់ធ្ងរគឺកម្រនឹងកើតមាន។

## ចុះទាក់ទងនឹងសុវត្ថិភាពវិញ?



- អ្នកមិនអាចកើតជំងឺ COVID-19 ពីថ្នាំបង្ការនោះទេ។ មិនមានថ្នាំបង្ការប្រភេទណាមួយមានផ្ទុកមេរោគដែលអាចបណ្តាលឱ្យកើតជំងឺ COVID-19 ទេ។
- ថ្នាំបង្ការទាំងអស់ត្រូវបានសាកល្បងចំពោះមនុស្សរាប់ម៉ឺននាក់ រួមទាំងមនុស្សដែលមានពណ៌សម្បុរផ្សេងគ្នា មនុស្សវ័យចំណាស់ និងមនុស្សដែលមានបញ្ហាសុខភាពប្រចាំកាយ ហើយបានរកឃើញថា **មានសុវត្ថិភាព និងមានប្រសិទ្ធិភាព**។
- ចាប់តាំងពីខែធ្នូ ឆ្នាំ 2020 មក **មនុស្សរាប់រយលាននាក់** បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដោយសុវត្ថិភាព។
- ថ្នាំបង្ការជំងឺ COVID-19 នៅតែបន្តឆ្លងកាត់ **ការត្រួតពិនិត្យផ្នែកសុវត្ថិភាពយ៉ាងល្អិតល្អន់បំផុត** នៅក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក។
- មិនមានភ័ស្តុតាងណាមួយដែលបង្ហាញថាថ្នាំបង្ការជំងឺ COVID-19 បណ្តាលឱ្យមានបញ្ហាមិនអាចមានកូននោះទេ។ ថ្នាំបង្ការទាំងនេះមានសុវត្ថិភាពសម្រាប់អ្នកដែលមានផ្ទៃពោះ និងត្រូវបានណែនាំឱ្យទទួលចាក់ដោយអ្នកឯកទេសផ្នែកផ្ទៃពោះផងដែរ។



VaccinateLACounty.com

County of Los Angeles Public Health
9-9-22 (Cambodian)